

ការពង្រឹងខ្សែសង្វាក់តម្លៃគ្រាប់ស្វាយចន្ទីនៅក្នុងខេត្តកំពង់ធំ

# ជំនួយឥតសំណង គូសាណូណិ

## ជំនួយឥតសំណងរបស់ជប៉ុន សម្រាប់គម្រោងទ្រង់ទ្រាយតូច សន្តិសុខមនុស្សជាតិ



ការសាងសង់បរិក្ខារសាលាមត្តេយ្យចំនួនប្រាំបីក្នុងខេត្តកំពត

## អំពីជំនួយឥតសំណងគូសាណូណិ

ជំនួយឥតសំណងគូសាណូណិ បាននិងកំពុងគាំទ្រប្រជាជនក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៩១ ក្នុងវិស័យ (១) ការអប់រំ (២) សុខាភិបាល និងការថែទាំវេជ្ជសាស្ត្រ (៣) កសិកម្ម (៤) ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងស្ពាន (៥) ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ (៦) ការបណ្តុះបណ្តាលវិជ្ជាជីវៈ និង (៧) សុខុមាលភាពសង្គម។

**ថវិកាជំនួយសម្រាប់គម្រោងនីមួយៗ៖**
រហូតដល់ ២០ លានយ៉េន ជាទូទៅ

**រយៈពេលអនុវត្តគម្រោងនីមួយៗ៖** រហូតដល់ ១ឆ្នាំ

## ស្ថាប័នដែលអាចដាក់ពាក្យបាន

រដ្ឋាភិបាលមូលដ្ឋាន
អង្គការក្រៅរដ្ឋាភិបាល
ស្ថាប័នសាធារណៈមូលដ្ឋាន
ស្ថាប័នអប់រំ
ស្ថាប័នវេជ្ជសាស្ត្រ ជាដើម។
✕ មិនមែនជាបុគ្គល ឬអង្គការរកប្រាក់ចំណេញ

## ទំនាក់ទំនងមកពួកយើង

**ស្ថានទូតជប៉ុនប្រចាំប្រទេសកម្ពុជា**
ក្រុមការងារសម្របសម្រួលជំនួយឥតសំណងគូសាណូណិ
ផ្នែកសេដ្ឋកិច្ច និងជំនួយអភិវឌ្ឍន៍ផ្លូវការ
ទូរស័ព្ទ៖ ០២៣ ២១៧ ១៦១
អ៊ីមែល៖ eco.jpn@pp.mofa.go.jp

វេបសាយ ហ្វេសប៊ុក



## ចំណាប់អារម្មណ៍

### កសិកម្ម



ប្រធាន
សហគមន៍កសិកម្ម

"ចាប់តាំងពីបញ្ចប់គម្រោង សហគមន៍យើងខ្ញុំបាននិងកំពុងប្រមូលផ្តុំកសិផល និងចែកចាយទៅកាន់ទីផ្សារជារៀងរាល់ថ្ងៃ។ វាបានរួមចំណែកធ្វើឱ្យជីវភាពកាន់តែប្រសើរជាងមុន។ សូមអរគុណដល់ការគាំទ្ររបស់ជំនួយឥតសំណងគូសាណូណិ។"

### ទឹកស្អាត

"គ្រួសារខ្ញុំមិនបាច់ចំណាយលុយទិញទឹកទៀតទេ។ យើងគ្រាន់តែមកយកទឹកពីកន្លែងចែកចាយទឹកដែលនៅជិតផ្ទះ។ ខ្ញុំអាចសន្សំលុយបានច្រើនសម្រាប់គ្រួសាររបស់ខ្ញុំ។ ទឹកដែលយើងប្រើរាល់ថ្ងៃគឺជាទឹកស្អាត និងមានសុវត្ថិភាពសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃរបស់យើង។"



ប្រជាពលរដ្ឋ

### សុខុមាលភាពសង្គម

"ការអាចពិនិត្យតាមដានកុមារពិការបានញឹកញាប់មានសារៈសំខាន់ខ្លាំងណាស់។ សូមអរគុណដល់ជំនួយឥតសំណងគូសាណូណិសម្រាប់ការផ្តល់រថយន្តគ្លីនិកចល័តមួយគ្រឿង ដែលឥឡូវនេះយើងអាចដាក់ឧបករណ៍វេជ្ជសាស្ត្រ និងបុគ្គលិកបានច្រើនជាងមុន និងអាចផ្តល់សេវាជូនកុមារពិការដែលរស់នៅក្នុងតំបន់ដូចគ្នាក្នុងពេលតែមួយបាន ទោះបីជាមានភ្លៀងក៏ដោយ។"



សេហ្វហេវិន (អង្គការក្រៅរដ្ឋាភិបាល)

# គម្រោងចំនួន៩ ក្នុងចំណោមគម្រោងចំនួន៥៦ ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២១ នៅក្នុងប្រទេសកម្ពុជា



ការបំពាក់ឧបករណ៍បោះពុម្ពអក្សរប្រៃយ៍នៅសាលាពិសេស ក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបាត់ដំបង និងខេត្តកំពង់ចាម (២០២០)



ការសាងសង់កន្លែងលាងដៃនៅក្នុងសាលារៀនចំនួន៦ នៅភាគខាងលិចនៃខេត្តស្ទឹងត្រែង (២០២១)





ការសាងសង់អគារសិក្សានៅអនុវិទ្យាល័យខ្យងក្នុងស្រុកជ័យសែន ខេត្តព្រះវិហារ (២០២១)



ការសាងសង់ស្ពានក្នុងឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ (២០២០)



ការសាងសង់អគារសម្ភពនៅក្នុងមណ្ឌលសុខភាពកំពង់ល្ពៅក្នុងខេត្តបាត់ដំបង (២០២០)



ការស្តារប្រព័ន្ធធារាសាស្ត្រកោះស្វាយ ក្នុងខេត្តកំពង់ចាម (២០២០)



ការកែលម្អផ្លូវក្នុងឃុំអណ្តូងទឹក ស្រុកបុទុមសាគរ ខេត្តកោះកុង (២០២០)



ការសាងសង់បរិក្ខារសាលាមត្តេយ្យចំនួនប្រាំបីក្នុងខេត្តកំពត (២០១៩)



ការកសាងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតបំពង់ខ្នាតតូច នៅកោះពាមរាំង ខេត្តព្រៃវែង (២០២១)

## ចំណាប់អារម្មណ៍

### សុខាភិបាល



"អគារនេះពិតជាជួយលើកកម្ពស់ការផ្តល់សេវាថែទាំសុខភាព ទាក់ទងនឹងសេវាសមធម៌ និងគុណភាពនៃការថែទាំនៅតំបន់ដាច់ស្រយាលនៃខេត្តព្រះវិហារ។"

ប្រធានមន្ទីរសុខាភិបាលខេត្ត

### ការអប់រំ

"ខ្ញុំសប្បាយចិត្តណាស់ដែលបានអង្គុយរៀននៅក្នុងអគារសិក្សាថ្មី ដែលមានបរិក្ខារគ្រប់គ្រាន់ និងចំនួនសិស្សសមរម្យ ដែលជាជំនួយឥតសំណងពីគម្រោងគូសាណូណិ។ ខ្ញុំទទួលបានការយកចិត្តទុកដាក់បន្ថែមពីលោកគ្រូអ្នកគ្រូដែលធ្វើឱ្យការសិក្សារបស់យើងល្អប្រសើរជាងមុន។"



សិស្ស

### ផ្លូវ

"សូមអរគុណដល់គម្រោងជំនួយឥតសំណងគូសាណូណិ ដែលបានកែលម្អផ្លូវជូនប្រជាជនក្នុងឃុំបុសមន និងឃុំពងទឹក ដែលសម្រួលដល់ការធ្វើដំណើរបានទាំងរដូវប្រាំង និងរដូវវស្សា និងចំណេញពេលវេលាច្រើនសម្រាប់សិស្សានុសិស្ស កម្មករ និងកសិករ ក្នុងការធ្វើដំណើររបស់ពួកគេ។"

មេឃុំពីររូប



